Khmer Story Lovers

ប្រលោមលោកប្រឌិតតាមសម័យបុរាណ ចិន

# ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ



ម៉ាណពមិនស្គាល់សម្លប៉ូវទេ តែនាយឃ្លានណាស់ ទើបមិនពិចារណាយូរ ឆក់ក្បាលភ្លាម ៗ នារីក្រោក ក្រោះដើរចេញទៅមួយស្របក់ លើកចាសម្លមួយទ្របាន សម្លក្ដៅហុយ ពោលក្លិនឈ្ងុយ ធ្វើឲ្យបុរសរឹតតែឃ្លាន លើសដើម ៗ នារីចូលមកដល់ពោលទាំងញញឹម :

- ប្រាំពីរថ្ងៃហើយ អ្នកប្រុសពិសាតែទឹកថ្នាំ ល្មមឃ្លានដែរមែនទេ ?

ពោលបណ្ដើរ នាងដាក់ចានលើតុក្បែរមាណព បណ្ដើរយ៉ាងគោរព ៗ ដោយសារពន្លឺទៀនធំៗ នាយឃើញដួបទឹកបបរសស្គុស មានចំណិតស្រពាប់ផ្កាកុលាបពីរបីសន្លឹកឲ្យក្រអូបទៀតផង ៗ ទឹកស៊ុបនេះជារបស់មានតម្លៃសម្រាប់អ្នកមានទ្រព្យសម្បត្តិ សេពសោយពេលមានជម្ងឺ ដើម្បីលើកកម្លាំង ៗ មាណពឆ្ងល់ណាស់ សួរទាំងញញើតញញើម :

-សម្លនេះឲ្យខ្ញុំហុតឬ ?

- ចាស ! សូមអញ្ជើញ ! មិនបាច់គួរសមទេ !

មាណពនឹកថា សម្លមួយចាននេះតម្លៃប៉ុន្មានទៅ ? យើងអត់លុយផងគោរងប្រាប់គេមុន កុំឲ្យខូចការ ៗ គិតឃើញដូច្នេះ នាយពោលភ្លាម :

អ្នកប្រែសម្រួល: អ.គីមសាន

តម្លៃ

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
«មាតុភូមិ»
ភ្នំពេញ

លេខ ៨

– ខ្ញុំគ្មានលុយមួយសេនទេណា៎ ! នាងកុំទារលុយខ្ញុំ ៗ

នារីស្រឡាំងកាំងមួយខណៈ ទើបសើចយឺសៈ

– ឈឺប៉ុណ្ណឹងហើយ នៅមិនព្រមបោលគំនិតចាស់ទៀត ! គ្រាន់តែហាមាត់និយាយបាន ក
តាំងតំប្លែងភ្លាម ! បើឃ្លានណាស់អញ្ជើញពិសាទៅ, កុំមាត់ច្រើនពេក !

នាងពោលផងរុញថាសទៅជិតអ្នកកម្លោះបណ្តើរ ៗ មាណពញញឹមបន្តិចសួរទៀតៈ

–ខ្ញុំហុតសម្លរមិនបាច់ឲ្យលុយទេឬ?

នារីបែបធុញទ្រាន់ណាស់ តបដោយទឹកមុខស្មើៈ

–មិនបាច់ទេ, ឥឡូវអ្នកប្រុសពិសាឬមិនពិសា ?

មាណពឆ្លើយញាប់មាត់ៈ

– ពិសា ! ពិសា !

ហើយលូកដៃចាប់ស្លាបព្រា តែនាយឈឺសព្វប្រាណក្លាម ស្រែកថ្ងូរហ៊ឺះ ទំរាំមាត់លើកស្លាបព្រា
ឥតបានសោះ ៗ នារីសួរដោយធុញទ្រាន់ៈ

– អ្នកប្រុសឈឺមែនឬធ្វើពើ ?

មាណពសួរដោយឆ្ងល់វិញៈ

–យីអើ ! ឈឺមែនណា៎ !

– ណ្ហើយ ! បើឈឺស្ទើរស្លាប់ស្ទើររស់មែននោះខ្ញុំ ប្រថុយបញ្ចុកម្តងទៀតចុះ ៗ តែប្រយ័ត្ន
ណា៎ ! កុំធ្វើផ្តេសផ្តាសទៀត, នៅឲ្យស្ងៀមទើបខ្ញុំបញ្ចុក ៗ កុំពិសណា៎ !

មាណពស្តាប់យូរ រឹតតែឆ្ងល់ សួរវិញៈ

– យី ! ខ្ញុំធ្វើអ្វីផ្តេសផ្តាស ? ពិសយ៉ាងម៉េច ?

នារីឡើងមុខក្រហមឆាំងសម្លក់ថ្ងៃ ហើយធ្វើហ៊ឺះនៅចុងច្រមុះ រួចទើបចាប់ស្លាបព្រាដួសទឹកស៊ុប
បញ្ចុកកម្លោះចំឡែក ៗ នាយក្រុមនេះមិនដែលបាននរណាថ្នាក់ថ្នមដូច្នេះទេ , នាយហាក់ល្ង
ល្ងើលើសដើម បណ្តាយឲ្យស្រីល្អបញ្ចុកដោយរកពាក្យសរសើរសំណាងដែលបានជួបនារីល្អ
ចំណែកនារីនោះវិញ ឈរឆ្ងាយពីគ្រែលូកដៃបញ្ចុកទឹកស៊ុបដោយប្រុងប្រយ័ត្ន ខ្លាចកោកនាយក្រុម
មានកាយវិការផ្តាំផ្តួនមកលើរូបកាយនាង ៗ មាណពលិទ្ធមាត់ក្លែម ៗ ពោលសរសើរៈ

-សម្លនេះឆ្ងាញ់មែន ! ឆ្ងាញ់ណាស់ ! សុំអរគុណនាងយ៉ាងច្រើន ។

នារីតបដោយសោះកក្រោះថា :

-អ្នកប្រុសកុំប្រើមពេញាបាយបោកបញ្ឆោតខ្ញុំណា ! ទឹកស៊ុបដូចតែគ្នាទេ, អ្នកប្រុសពិសារពប់ពាន់ចានទៅហើយមិនដែលសរសើរម្ដងទេ ។

មាណពឆ្លល់លើសដើមដណ្ដឹងសួរ !

-សម្លឆ្ងាញ់បែបហ្នឹងយើងស៊ីពីអង្កាល់ហ្ន៎?

នាយសួរនារីទៀត:

- អូ ! អាហ្នឹង គេហៅទឹកស៊ុបឬ ? គេហុតឲ្យវា យ៉ាងម៉េចដែរ?

- ហុះ ! អ្នកប្រុសប្រសប់ធ្វើពើណាស់ !

នារីថយមួយជំហានទៀតហាក់ខ្លាចលោកនាយគ្រុមណាស់ ។ ចំណែកមាណពសង្កេតមើលនារីតាំងពីក្បាលដល់ចុងជើង ឃើញនាងពាក់អាវដៃខ្លីបញ្ចេញសាច់សទ្រលុក, បងស់ក់ញែកជាពីរទម្លាក់លើស្មា ហើយនាងដើរជើងទទេបង្ហាញសាច់សថ្លា នាយពេញចិត្តក្រៃលែងព្រោះមិនធ្លាប់ឃើញនារី, នាយគ្រាំមិនបានពោលសរសើរគេថា :

- នាង . . . នាងល្អមើលណាស់ !

នារីទឹងគ្រហមមុខទម្លាក់ស្លាបព្រាពេលលើតុងាកក្រោយដើរតម្រង់កន្ថែលខ្មើយ ប្រមូលចេញទៅក្រៅបាត់ ។ មាណពភ្ញាក់ព្រើតស្រែកហៅ :

- អេ ! នាងទៅណាហ្នឹង ? លែងរស់នឹងខ្ញុំហើយឬ ?

នារីងាកមុខមកឆ្លើយ :

- អ្នកប្រុសឈឺស្ទើរស្លាប់សំកកស្ងៀមមួយកន្លែងយូរថ្ងៃហើយ ខានលេងពាក្យសំដីយូរឬបានជាប្រញាប់ផ្ដោះផ្ដងម្ល៉េះ ? ខ្ញុំមិនអាចទៅណាទេ ព្រោះខ្ញុំជាបំរើ អ្នកប្រុសជាចៅហ្វាយ ។ នរណាហ៊ានឈប់រវល់នឹងអ្នកប្រុស ?

ពេលចប់នាងដើរចេញត្រូយទៅ, មាណពទឹងចិត្តណាស់មិនដឹងខ្លួនធ្វើអីខុសបានជានារីទឹងម្ល៉េះ ? អើហ្ន៎ ! ម្នាក់លោតតាមបង្អួច ម្នាក់ចេញតាមទ្វារ ហើយមួយណាដូចមួយណា និយាយមកយើងស្ដាប់មិនបានសោះ ! ហ៊ឺ ! គេធ្វើអីហ្នឹងយើងមិនយល់ទេ ។

ពេលនោះព្យុះភ្លៀងស្រិចៗ តំរង់មកទៀត គឺនារីដែលកាន់ចានដែកដាក់ទឹកពេញចូលមកចាំងមុខក្រមុំ, មាណពអរកើតបាត់ភ័យបន្តិចវិញ ។ នារីដាក់ចានដែកលើតុហើយលើកកន្សែងមួយពូតហុចឲ្យនាយ ជាមួយវាចា :

- ជូតមុខទៅ!

កម្លោះឆ្លើយញាប់មាត់ថាបាទ! បាទ!

ហើយលូកដៃទទួលកន្សែងក្តៅឧណ្ហៗ ក្តាម តែនាយកម្រើកដៃបន្តិចឈឺពេញខ្លួនទៀត នាយមានះ ចាប់កួនកន្សែងទាល់តែបាន ។ លុះនាយលើកជូតមុខដៃញ័រទទ្រើក ជូតមិនកើតមែនទែនធ្វើឲ្យនារីមានការសង្ស័យ ពោលបែបចំអក :

- ប្រុសប់ធ្វើឫកមែន!

នាងយកកន្សែងពីដៃមាណព ហើយពោលបញ្ជាក់ :

- ខ្ញុំជូតមុខជូនអ្នកប្រុសបានដែរតែកុំលូកលាន់ខ្ញុំណា! ប៉ះតែសក់មួយសរសៃគឺខ្ញុំស្បថលែងជាន់បន្ទប់នេះដែរ ។

- ខ្ញុំមិនហ៊ានប៉ះនាងទេ, ឥឡូវកុំជូតអីមុខខ្ញុំកខ្វក់ណាស់ ឯកន្សែងនេះ សស្អាតក្រៃប្រឡាក់អស់ទៅណា!

នារីសង្ស័យទ្វេឡើងទឹកថា :

-សំដីគាត់ខុសប្រក្រតីអីចឹងបែបខូចខួរក្បាលហើយដឹង? យើងព្រលោកគ្រូពេទ្យថាអ្នកប្រុសរបួសដល់ប្រដាប់ប្រដាក្នុងខ្លួនអស់ហើយ, ឈឺម្ដងនេះធ្ងន់ក្រៃលែងប្រហែលឡប់សតិអារម្មណ៍មែន!

នាងអត់មិនបានសួរតិចៗ :

-អ្នកប្រុស ... ចាំឈ្មោះខ្ញុំទេ ?

- អើហ្ន៎! នាងមិនប្រាប់ខ្ញុំផងសួរមុនអីចឹងឬ? ម្យ៉ាងទៀតខ្ញុំមិនមែនឈ្មោះនាយក្រុម ឬអ្នកប្រុសអីទេ, ខ្ញុំឈ្មោះថ្កុតតពូជ ម៉ែខ្ញុំហៅអីចឹងតាំងពីតូចមក តែអីខ្ញុំថាមិនពីរោះស្ដាប់ទៅវិញ ។ ចុះនាងឈ្មោះអី ?

នារីរឹតតែឆ្ងល់ជ្រួញចិញ្ចើមនឹក :

- មើលឫកពា ទិនសំដីសំដៅដូចជាមិនធ្វើពើ ឬ ឆ្កោះឆ្កួតដាក់យើងទេ, គាត់នេះវង្វេងស៊ីន

ក្លាយជាមនុស្សល្ងីល្ងើហើយឬ ?

នាងគិតណាស់រឹតតែពិបាកណាស់សួរម្តងទៀត:

– អ្នកប្រុសមិនស្គាល់ខ្ញុំមែនឬ ? ខ្ញុំឈ្មោះតាយជានណា៎ ! អ្នកប្រុសភ្លេចហើយ ?

– ឈ្មោះតាយជាន ? ថ្ងៃក្រោយខ្ញុំហៅតាយជានៗហើយ ។ ទេ . . . ហៅបងតាយជានវិញ ព្រោះម៉ែខ្ញុំប្រាប់ថាមនុស្សស្រីអាយុច្រើនត្រូវខ្ញុំហៅលោកយាយឬអ្នកមីង បើអាយុប្រហែលគ្នាត្រូវហៅបង ។

នាងតាយជានទុនមុខជ្រប់សម្រក់ទឹកភ្នែកយំខ្សឹកខ្សួល:

– អ្នកប្រុសមិនកុហកទេឬ ? ពិតជាភ្លេចឈ្មោះខ្ញុំមែន ! ហ៊ឺ . . . ហ៊ឺ . . .

មាណពតក់យស្ញោសួរភ្លាម:

– ម៉េចក៏ចឹង ? បងយំរឿងអីប្រាប់ខ្ញុំផង ។ ខ្ញុំថាអីបានជាបងពិបាកចិត្ត ? ម៉ែខ្ញុំតែងម្តងៗ គាត់ដេរវាយខ្ញុំហើយ ! ឥឡូវបងដេរខ្ញុំក៏បានវាយខ្ញុំក៏បាន ។

តាយជានថ្លួលចុងប្រមុះពិបាកចិត្តខ្លាំងឡើង លើកកន្សែងជូតទឹកភ្នែក ហើយយំឈឺគឈួក បណ្តើរពោលបណ្តើរ:

– ខ្ញុំជាស្រីបំរើ មិនអាចដេរ ឬវាយអ្នកប្រុសបានទេ ។ ខ្ញុំបន់ឲ្យតែទេពតាជួយអ្នកប្រុសជាស្រឡះពីជម្ងឺចង្រៃនេះទៅ ។ បើអ្នកប្រុសភ្លេចអស់លើងអីចឹងធ្វើម៉េចទៅ ?

មាណពភ្លើភ្នែកឡិងឡង់, តាយជានបន្ត:

– អ្នកប្រុសភ្លេចឈ្មោះខ្ញុំ តែនៅចាំរឿងផ្សេងៗទៀតដែរ? ឧមាថាអ្នកប្រុសជានាយក្រុមមាននាមអ្វី ?

មាណពនៅតែគ្រវីក្បាលប្រកែក: .

–ខ្ញុំមិនមែននាយក្រុមទេ ! អ៊ឹខ្ញុំបង្ហាត់វិជ្ជាគុន ស្រាប់តែចេញចំហាយមួយចំហៀងក្តៅ មួយចំហៀងត្រជាក់ពិបាកទ្រាំក្រៃលែង ទាល់តែសន្លប់ហ្នឹងណា៎ ! បងនាំខ្ញុំមកទីនេះឬ?

តាយជានអាណិត «នាយក្រុម» ខ្លោចចិត្តនឹកថា គាត់ភ្លេចអ្វីៗអស់ហើយ ! . គ្មានសង្ស័យទេ ។

មាណពសួរតទៀត :

- ចុះអ៊ំខ្ញុំទៅណាហើយ ? គាត់ឲ្យខ្ញុំហាត់តាមកូនតក្កតាស្រាប់តែក្តៅដូចភ្លើង រួចពីក្តៅត្រជាក់ដូចទឹកកក ៗ ខ្ញុំចង់សួរគាត់មើលហេតុអីពិបាករៀនម្ល៉េះ ?

តាយជានអៀនក្រហាមមុខ នឹកឃើញកាលនាងផ្លាស់ខោអាវឲ្យនាយក្រុមពីអាទិត្យមុន ៗ នាងឃើញកូនប្រអប់ឈើមួយមានសុទ្ធតែកូនមនុស្សស្រាតនទល ៗ លាបកំបោរសចំនួនដប់ប្រាំបី នាងនឹកថា: លោកនាយក្រុមល្មោភកាមតណ្ហាណាស់បានជាមានល្បែងបោកបាចបែបហ្នឹង ៗ នាងមិនហ៊ានមើលក៏បិទប្រអប់ទុកក្នុងបតតុទៅ ៗ ឥឡូវឮអ្នកប្រុសរំឭករឿងតក្កតា នាងបើកបតតុយកប្រអប់មកសងវិញព្រមទាំងសួរ :

- កូនតក្កតាក្នុងប្រអប់នេះឬ?

- អ៊ីហ្នឹងហើយ ៗ ចុះលោកអ៊ំទៅណា ?

- អ៊ំណាមួយ ?

- អ៊ំខ្ញុំណា! មានតែមួយទេ គាត់ជាម្ចាស់ក្នុំម៉ាន ៗ

តាយជានមិនស្គាល់អ្នកក្លាហានក្នុងពិភពគុនមែនតែម្ចាស់ក្នុំម៉ានល្បី ល្បាញយូរឆ្នាំហើយត្រូវជាប់ពាក់ទងក្នុងរឿងនាយក្រុមថ្មីៗនេះផង ក៏អាចគាត់យល់ថានរណាដែរ ៗ នាងឆ្លើយថា :

-អ្នកប្រុសដឹងខ្លួនប៉ុណ្ណឹងទុកជាសំណាង ហើយកុំខំរកនឹករឿងចាស់ពេកសូមសំរកចុះ ៗ តែបើនឹកមិនឃើញល្អជាង !

ពោលចប់នាងលើកពានដែកនិងចាសដើរចេញទៅ , មាណពសួរ :

- បងតាយជាន ! ហេតុអីបានជាថាខ្ញុំនឹកមិនឃើញល្អជាង ?

- ព្រោះកាលមុនអ្នកប្រុស ...

ពោលបានតែប៉ុណ្ណោះនាងល្ហាកមុខដើរចេញយ៉ាងលឿន , មាណពនៅក្នុងបន្ទប់ម្នាក់ឯងឆ្ងល់នឹងព្រឹត្តិការណ៍ថ្មីៗណាស់ ៗ ខណៈនោះឮសម្លេងគោះគ្រដោកលាន់ពីចម្ងាយប៉ុងប្រាប់ថាយាមបីហើយ ៗ កម្លោះនេះល្ងង់ណាស់នឹកឆ្ងល់ថាហេតុអ្វីយប់ជ្រៅថ្មើរណេះ មានគេវាយឃ្មោះលេងទៀត ៗ

រំពេចនោះស្រាប់តែនាយចាប់អារម្មណ៍ក្តៅខ្លួល ពីម្រាមដៃដល់ស្មា ហើយធាតុត្រជាក់ជ្រាបចូលតាមបាតជើងរត់ឡើងស្រឹត ៗ ដល់ចុងដង្ហើមទើបប៉ះធាតុក្តៅប្រឆាំងគ្នាយ៉ាងសាហាវ បណ្ដាលឲ្យមាណព

ឈឺចាប់ឥតឧបមា ព្រោះមុនៗ អាការកេតនេះធ្វើទុក្ខតែពេលនាយសន្ធប់សន្ធិន មិនសូវជឹនឥឡូវពេលវាទេ គ្រាន់តែចាប់ផ្ដើមភ្ញាក់ នាយតែងទ្រាំមិនបានសន្ធប់បាត់ស្មារតី ។ ម្ដងនេះនាយក៏យកគក្កមាដោយហេតុធាតុទាំងពីរមកជុំគ្នាត្រង់ចុងជង្ហើមកន្ទែងប្រជុំជីពចរ ។នាយនឹកថា :

– ម្ដងនេះចៀសមិនផុតពីក្ដីស្លាប់ទេ ។

យល់ឃើញបែបនេះក៏ខំស្ទុះបំរះរកដើមអង្គុយពេនភ្នែនទប់ទល់ តែជើងនាយស្ពឹកអស់ទៅហើយមិនអាចអង្គុយបានស្រួលទេ ។

ក្នុងគ្រាដ៏លំបាកនេះនាយដណ្ដឹងសួរ:

– កាលលោកអ៊ំហាត់រៀនគាត់លំបាកដូចនេះដែរឬ ? គាត់យាត់បាបមិនឲ្យហើរផុតបាតដៃឃើញថាសប្បាយណាស់, តែបើដឹងពីបាកអីចឹងយើងមិនខំរៀនទេ !

ខណៈនោះនាយឮសម្លេងបុរសម្នាក់ពោលតិចៗនៅមាត់បង្អួច :

– លោកនាយក្រុមភ្ញាក់ហើយឬ ? ខ្ញុំបាទចានហៃនាយត្រួតក្រុមខ្វារទិនមានកិច្ចការសំខាន់ចង់ជួបលោក ។

មាណពនៅស្ងៀម ព្រោះនិយាយមិនចេញ ។ ភ្លាមនោះឃើញបង្អួចបើកសន្សឹមៗហើយបុរសម្នាក់លោតផ្លោះចូលមកក្នុងបន្ទប់ ។ គេស្លៀកពាក់ខោអាវក្រវេមក្រវាមដូចស្បែកខ្លាដើរតំរង់គ្រែតែម្ដង ។ ទៅជិតដល់ទើបឈប់ដំណើរឈរមើលលោកនាយក្រុមដែលដេកស្ងៀមបើកភ្នែកក្រឡោតមើលមក ។ មាណពឈឺចាប់ក្រៃលែងក្ដៅក្រហាយស្ទើរគ្មានពីបាកទ្រាំទ្រមែន តែនាយខំបើកភ្នែកក្រឡោតតាមមើលសកម្មភាពចានហៃឥតព្រិច ។ នាយត្រួតចានហៃខាងក្រុមខ្វារទិនពោលតិចៗទៀត :

– ខ្ញុំឮថាលោកនាយក្រុមមានជម្ងឺធ្ងន់ណាស់, ឥឡូវធូរស្រាលហើយឬ? ខ្ញុំត្រេកអរណាស់ ។

មាណពដេកស្លូកដដែលឥតនិយាយស្ដី, ចានហៃអរកើតសួរទៀត:

លោកនាយក្រុមមិនទាន់ជាស្រួលបួលទើបកំរើកមិនបានមែនទេ ?

ពេលនោះនាងតាយផានដែលសម្រាកក្នុងបន្ទប់ក្បែរគ្នាឮសម្លេងប្លែក នាងក្រោកមកមើលភ្លាមឃើញចានហៃបញ្ចេញទឹកមុខកាចសាហាវដាក់នាយក្រុម នាងក៏យញាប់ញ័រសួរភ្លាម :

– លោកចូលបន្ទប់នាយក្រុមធ្វើអីបើគ្មានបញ្ជា ? លោកមិនខ្លាចច្បាប់ទម្លាប់ទេឬ ?

តានហៀវឥតនិយាយច្រើន ស្ទុះហោះទៅចុចជីពចរនាងក្តាម ៗ តាយជានបេះគុនវិជ្ជាបន្តិចបន្តួចគ្រាន់ការពារខ្លួនដែរ តែនាងមិនអាចទប់ទល់ស្នៀតដ៏រហ័សរបស់តានហៀវបានឡើយ ៗ តានហៀវដាក់នាងផ្តួលលើកៅអី ហើយយកកូនកន្សែងចុកមាត់នាងជិត ៗ ដល់ពេលនេះទើបនាងតាយជានភ័យមែនទែន យល់ថាគេមានបំណងអាក្រក់ចំពោះនាយក្រុមខ្លួនហើយ តែចាំងស្រែកហៅគេជួយមិនបាន ៗ តានហៀវនៅញញើតនាយក្រុមទៀតបានជាលើកដៃកំញើញនាងថា:

- វិជ្ជាដៃជើងរបស់យើង អាចទះឯងស្លាប់នឹងកន្លែងណា៎ !

ពោលផងទះរូសំដៅក្បាលនាងផង សង្ឃឹមថា បើនាយក្រុមមានកម្លាំងប្រហែលដើម ពិតជាស្ទុះមកជួយការពារស្រីបំរើពុំខាន ៗ លុះឃាតដៃគេជិតទៅដល់ក្បាលតាយជាន មាណពនៅដេកស្ងៀមដដែលគេដកខ្លួនចេញក្តាម ងាកមកសើចចំអកដាក់លោក «នាយក្រុម»:

- ម៉េចអាចោរតណ្ហាក្រាស់? មួយជីវិតនេះឯងប្រព្រឹត្តអំពើអនាចាររាប់មិនអស់ទេ ៗ ឥឡូវឯងធ្លាក់ក្នុងកណ្តាប់ដៃយើងហើយ !

តានហៀវបោះជំហានចូលជិតគ្រែពោលបន្ត:

- ឯងគ្មានកម្លាំងទប់ទល់នឹងយើង, យើងសម្លាប់ឯងទៅគ្មានឈ្មោះថាអ្នកក្លាហានទេ ៗ ប៉ុន្តែគំនុំយើងជ្រៅដូចមហាសមុទ្រ យើងមិនត្រូវយកច្បាប់ពិភពគុនមកអនុវត្តទេ ៗ បើឯងស្គាល់ច្បាប់ទម្លាប់ ម៉េចនាំប្រពន្ធអញឲ្យលង់ខ្លួនក្នុងជ្រោះកខ្វក់ ?

មាណពនិងតាយជានកំរើកប្រាណមិនកើត តែស្តាប់ឮទាំងអស់, មាណពដណ្តឹងសួរ :

- ម៉េចទៅគំនុំជ្រៅដូចសមុទ្រ ? ហេតុអ្វីគាត់ថាយើងនាំប្រពន្ធគាត់ឲ្យលង់ខ្លួនក្នុងជ្រោះ ?

តាយជាននឹកម៉្យាង :

- អ្នកប្រុសល្មោភកាមគុណ ជំពាក់បំណុលគេច្រើនណាស់ ៗ យប់នេះគេមកជំរះបញ្ជីដល់កន្លែងហើយ, អ្នកប្រុសស្លាប់ឥឡូវហើយ ?

នាងភ័យពេកចង់បំរះ តែដៃជើងស្ពឹកអស់ហើយ ចំប្រឹងស្ទុះស្ទាពេកពាល់តែធ្លាក់ពីកៅអី ៗ

តានហៀវពោលទាំងកំហឹង :

- ហ៊ឹះ ! ប្រពន្ធយើងខូចខ្លួនប្រាណដោយសារឯង ! ឯងកុំស្មានថាយើង «អាវែក» គ្មានដឹងខ្យល់អីណា៎ ! យើងទំលេបទុក្ខព្រោះយើងជឿថា ទេវតាមានភ្នែកអាចជួយដោះទុក្ខអ្នកទន់ខ្សោយ...

ឥឡូវថ្ងៃអន្សាឯងមកដល់ហើយ ។ ឯងគេចមិនផុតទេ អាចោរគណ្ហាក្រាស់ ។

ពានហ្វៃជានាយត្រួតក្រុមខ្វាវចិនក្នុងបក្សឈានល្អ គាត់បេះវិជ្ជាដៃជើងកខ្លាំងពូកែណាស់គាប់ ទះកំទេចជុំថ្ពាន ។ ពេលនេះគាត់បំភ្លឺនកម្លាំងលាន់ផ្គឹងប្រឹប ៗ បញ្ចេញចាំងផប់កាត់ទុះវ៉ូតម្រង់ ចង្កេកទ្រូងមាណព ដែលដេកស្មៀមលាន់ផាំង ។ ហើយក្រាក ។ ដៃស្ដាំពានហ្វៃបាក់ខ្ទេច , រាង កាយគាត់ប៉ើងខ្ទាតប៉ះបង្អួចបាក់ប្រាវ ។ ទៅធ្លាក់ក្នុងសួនច្បារក្បែរនោះចាំងអស់ ។ ពានហ្វៃស្ទុះ ដង្ហើមសន្ធប់បាត់ស្មារតីធ្វើឲ្យផ្អើលកូនចៅគាត់ចាំងអស់ ដែលយាមវាងក្រៅ ។ រាត្រីនេះ ត្រូវវេនក្រុមខ្វាវចិនយាមទើបពានហ្វៃអាចចូលដល់បន្ទប់លោកនាយក្រុម ។

ពេលនេះសេនាចាំងអស់ផ្អើលនោទ្យាកាន់បន្ទុះ រត់មកមើលឮអ៊ូអរឃើញនាយត្រួតសន្ធប់ក៏ស្មាន ជាមានសត្រូវចូលដល់កន្លែងលោកនាយក្រុមហើយ ។ អ្នកខ្លះដកកាំភ្លើងប្រកាសសញ្ញាអាសន្នអ្នកខ្លះ ហូតកាំបិតលំពែងក្បាលមើលក្នុងបន្ទប់លោកនាយក្រុម ។ បន្ទប់នេះងងិតស្ងប់ស្ងាត់ឈឹង ។ គេលើកបន្ទុះ បញ្ចាំងមើលសព្វកន្លែងព្រមចាំងដើរលបៗចូលទៅឃើញលោកនាយក្រុមអង្គុយពែនភ្នែន លើគ្រែនឹងនារីម្នាក់ជួលក្បែរនោះមុខដូចស្រីបំរើ ។ ក្នុងពេលជាមួយគ្នាសមាជិកក្រុមឈានល្អ ផ្អើលល្បូងរត់ សំដៅបន្ទប់លោកនាយក្រុមជាបន្តបន្ទាប់គ្នា ។ ឈើវសានហ៊ុននាយត្រួត ខាងក្រុមខ្វាកំណាចដកកាំរុងស្រែកសួរមុន :

– លោកនាយក្រុមមានរឿងគ្រោះទេ ?

គេនាំគ្នាបង្ហើបទ្វារចូលក្នុងបន្ទប់ត្រូវពេលមាណពរឹតតែញ័រកាយលើសដើម ហើយស្រែកថ្ងូរ ព្រួសឈាមពណ៌ស្វាយបេញមកយ៉ាងច្រើន ។ សានហ៊ុនគេចភ្នែកផុតពីឈាមស្វាយធ្លុចហួង ថែមចាំងស្រឡាំងកាំងដូចអ្នកឯទៀត ។ លោកនាយក្រុមស៊ីស្ទុះចុះពីលើគ្រែលើកស្រីបំរើឲ្យ អង្គុយវិញព្រមចាំងសួរ :

– បងគាយជាន . . គាត់មានធ្វើឲ្យបងរបួសទេ ?

ស្ទួរផងដកកំណាត់បេញពីក្នុងមាត់នាងចេញផង ។ គាយជានដកដង្ហើមយូរឆ្លើយ :

– គាត់មានវាយអ្នកប្រុសរបួសដែរ ?

– គាត់ទះខ្ញុំមួយដៃ ខ្ញុំស្រួលខ្លួនជាងមុនច្រើន ។

ខណៈនោះស្នូរជើងកាន់តែច្រើននៅក្រៅបន្ទប់គឺ សមាជិកចាំងអស់រត់មកសួរដំណឹង ។ តៃហាស៊ី

និង ទីហ៊ុងយេ ស្ទុះចូលក្នុងបន្ទប់សាកសួរមាណព :

- មានសត្រូវលបចូលមកយាយីលោកនាយក្រុមឬ ?

-ពួកសត្រូវអី ? គ្មានទេ !

ពេលនោះគេជួយតានហៃឲ្យភ្ញាក់ស្មារតីហើយជួយគ្រាហ៍ចូលបន្ទប់ដេក ។ តានហៃស្គាល់កំហុសខ្លួនណាស់ គឺតាមទម្លាប់ក្រុមឈានលួអ្នកណាក្បត់នាយក្រុមត្រូវទទួលទារុណកម្មព្រៃផ្សៃបំផុត ។ គេតែងចាប់សំពតខោអាវអ្នកជាប់ទោស រួចយកទៅចងនឹងសសរថ្មមួយដែលគេឲ្យឈ្មោះថាកន្លែងកាត់ទោសហើយទុកចោលទីនោះឲ្យស្រមោចខាំនិងសត្វខ្លែងឬត្មាតចោះស៊ីតាមចិត្ត ទាល់តែរងទុក្ខច្រើនថ្ងៃទើបអ្នកទោសអស់ជីវិត ។

អម្បាញ់មិញតានហៃបញ្ចេញកម្លាំងអស់ពីខ្លួនទះលោកនាយក្រុម ប្រាថ្នាយកជីវិតគាត់សងជម្ងឺចិត្ត ផ្ទាល់តែបែរជារងគ្រោះបាក់ដៃនិងរបួសគ្រាំគ្រាក្នុងកាយទៀត ។ គាត់បន់ឲ្យស្លាប់ភ្លាម ៗ ទៅស្រាប់តែគេនាំគាត់ចូលបន្ទប់លោកនាយក្រុមវិញ ។ គាត់បំរើនកម្លាំងធាតុសម្រេចការឈឺចាប់រង់ចាំតែលោកនាយក្រុមហាមាត់បញ្ជាឲ្យបញ្ជូនទៅកន្លែងកាត់ទោសនឹងអាលបោកក្បាលសម្លាប់ខ្លួន ។

តៅហៃស៊ុសួរលោកនាយក្រុមមុនគេ:

-សត្រូវលោកតាមបង្អួចមកឬ ?

- ទេ, ខ្ញុំកំពុងដេកលក់ដូចជាគ្មានសត្រូវណាទេ ...

តានហៃព្រួចខ្ជេះធ្ងល់ណាស់នឹកថា:

- នាយក្រុមនេះប្រែក្លាយជាល្ងីល្ងើមែនឬ បានជាមិនដាក់ទោសយើង ? ចាំមើលស្រីបំរើនិយាយការពិតឬទេ ?

មែន! តៅហៃស៊ុស្រាយជីពចរឲ្យតាយជានរួចសួរ :

- អ្នកណាចុចជីពចរឯង !

តាយជានបន្ទុលតានហៃ , តៅហៃស៊ុសម្លឹងតានហៃដោយសង្ស័យជាខ្លាំង ។ តានហៃធ្វើហ៊ុះ! ប្រុងស្រែកដេរឲ្យស្លប់មាត់ ព្រោះដឹងច្បាស់ថា ចៀសមិនផុតក្តីស្លាប់ , តែនាយក្រុមពោលមុន :

- ខ្ញុំ... ខ្ញុំឲ្យគាត់ធ្វើអីចឹងណា៎ !

តានហ្វៃនិងតាយផានភ្ញាក់ព្រើតស្រឡាំងកាំងរៀនខ្លួនស្ទើរមិនជឿត្រចៀកទេ ។ គេសម្លឹងមុខមាណពព្រមគ្នា លែងយល់សោះតែម្តង ។ មាណពវិញមិនយល់រឿងហេតុដែលអាចកើតមានឡើងដែរ, តែនាយចាប់អារម្មណ៍ចំឡែកដូចមានអ្វីប្រាប់ថារឿងធំណាស់ នាយឃើញគេគោរពកោតខ្លាចនាយណាស់បើឲ្យដឹងថាតានហ្វៃចុចដីពបទានីតាយផាន ហើយទះនាយមួយដៃនោះច្បាស់ជាអ្នកអស់នេះធ្វើបាបតានហ្វៃមិនខាន ម៉្លោះហើយនាយកុហកគេទៅ ។

នាយធ្វើបែបនេះក្នុងគោលបំណងតែមួយគត់ គឺជួយការពារតានហ្វៃ ដើម្បីសងគុណគាត់ដែលបានទះនាយមួយដៃស្រួលខ្លួនលើសធម្មតា ។ ក្បែតមុននេះបន្តិចជាតុក្កតាទីនត្រជាក់ធ្វើទុក្ខខ្លាំងពេក រឹះក្បែយសន្ធារ នាយអស់សង្ឃឹមលើងពីខ្លួនមិននឹកថាក្នុងមួយប៉ប្រិចភ្នែក នាយមានកម្លាំងលើសដើមអស់ពិបាកដូចមុន, កម្លាំងនាយកើនរហូតរុញច្រានតានហ្វៃឲ្យខ្ទាតដល់ក្រៅ ។ នៅពេលឈើរសានហ្វុងមកដល់នាយស្ទុះបំពង់កទើបព្រួសឈាមពណ៌ស្វាយមួយគំនរពោល រឹតតែបានភ្លឺស្វាងតែថែមទៀត ។

មាណពប្រែក្លាយជាអ្នកមានកម្លាំងកាយស្តុកស្តម្ភ បានប្រាជ្ញាស្មារតីភ្លឺស្វាងលើសដើម, តែពៅហៃស៊ីសង្កេតឃើញនាងតាយផានបញ្ចេញកេការៈភិតភ័យ ហើយឃើញខោអាវខ្ទេចខ្ទីសក់ក្បាលកន្ទ្រើងគាត់យល់ឆ្ងល់ថា លោកនាយក្រុមល្ងោភកាមតណ្ហា ប្រហែលមានកម្លាំងបន្តិចបន្តួចស្រែកឃ្លានសម្ផស្សនាងតាយផានទេដឹងបានជាហៅ តានហ្វៃ ឲ្យចុចជីពបរជំនួសគាត់ ? តែហេតុអ្វីក៏តានហ្វៃបាក់ដៃ ហើយខ្ទាតដល់ក្រៅបន្ទប់សន្ទប់ថែមទៀត ? សមាជិកក្រុមឈានល្អ តាំងអស់ដែលនៅជុំវិញក៏នឹកស្មានដូច្នេះដែរ ព្រោះលោកនាយក្រុមកាចសាហាវឃោរឃៅណាស់, ពេលខឹងក្រោធម្តង ៗ គាត់គ្មានស្គាល់អ្នកតូចអ្នកធំទេ ឲ្យតែនៅជិតសុទ្ធតែត្រូវគាត់យារជើងឬដៃទាត់ធាក់ឥតយោគយល់ឡើយ ។

ពេលនេះគេឃើញតានហ្វៃរបួស ហើយដៃជើងប្រឡាក់ឈាមពាសពេញ គេអាណិតសហការីណាស់ តែគ្មាននរណាហ៊ានចូលទៅសាកសួរសុខទុក្ខគាត់ នៅចំពោះមុខលោកនាយក្រុម , ជាពិសេសឈើរសានហ្វុងដែលមកដល់មុនគេ ។ គាត់យល់ថា គាត់មករំខានលោកនាយក្រុមក្នុងពេលលោកត្រេកត្រអាលរសជាតិកាមគុណ ម៉្លោះហើយគាត់ខ្លាចរងគ្រោះដូច តានហ្វៃ ក៏លុតទនកាយគោរពមុនគេ :

- សូមលោកនាយក្រុមសំរាកចុះ, ខ្ញុំបាទសូមលា ។

អ្នកឯទៀតប៉ប្រាប៉ក់បលាបន្ទប់ខ្ទប់គ្នា នៅសល់តែតៃហស៊ីម្នាក់គត់ ដែលឈឺក្បាលខឹងសុខភាពលោកនាយក្រុម ដោយឃើញទឹកមុខលោកប្រែប្រួលខ្លាំងពេក ។ គាត់លូកដៃថ្នមៗ សុំអនុញ្ញាតស្ទាបជីពចរមើលម្ដងទៀត, លោកនាយក្រុមហុចដៃឲ្យពិនិត្យតាមត្រូវការ ។ តៃហស៊ីរីករាយណាស់ដោយហេតុលោកនាយក្រុមបានស្មារតីភ្ញាក់ស្វាងជាងមុន, គាត់លូកប្រាមដៃបីស្ទាបជីពចរភ្លាម ។ គ្រាន់តែប៉ះសាច់មាណពលោកគ្រូពេទ្យញ័រដៃស្ពឹកមួយចំហៀងខ្លួនភ្លាម ធ្វើឲ្យគាត់ភ្ញាក់ក្រញាងហក់ថយក្រោយយ៉ាងរហ័ស ។ ត្បិតកម្លាំងកាយមាណពធ្វើចលនាជាស្វ័យប្រវត្តិរុញកម្លាំងដៃឲ្យខ្ទាតមករកក្រៅនោះឯង ។ តៃហស៊ីពោលទាំងអំណរ:

- សាធុ! សាធុ! លោកនាយក្រុមហាត់រៀនវិជ្ជាដំខ្លួនខ្លួសបានសម្រេចហើយ ។

មាណពស្រឡាំងកាំង:

- វិជ្ជា . . . ដំខ្លួនខ្លួសស្អី ?

តៃហស៊ីស្មានថាលោកនាយក្រុមមិនចង់ឲ្យលេចដំណឹងខ្ចរខ្ចាយទើបគាត់មិនហ៊ានរំពុក:

- ខ្ញុំនិយាយផ្ដេសផ្ដាសទេ, សូមលោកនាយក្រុមមេត្តាអភ័យទោស ។

ពោលចប់គាត់លំនូនកាយចាកចេញពីបន្ទប់ទៅ ។ ឥឡូវនៅសល់តែចានហ្វា និងតាយផានទេ ។ ចានហ្វាបាក់ដៃឈឺបែកញើសជោកខ្លួន ឥតហ៊ានហើបមាត់ជាមេបឡើយ ព្រោះខ្លាចបញ្ហាពីលោកនាយក្រុម ។ លុះគេចេញអស់ គាត់ទ្រាំលែងបានប្រថុយទាំមាត់ស្រែកថា:

- ឯងចង់ធ្វើបាបយើងបែបណាធ្វើមកចុះ, ត្រកូលចាននេះមិនខ្ចីអង្វរឯងមួយម៉ាត់ទេ ។

មាណពសួរដោយឆ្ងល់:

- ហេតុអ្វីបានខ្ញុំត្រូវធ្វើបាបលោក ? រឿងនេះបាក់ហើយឬ ? មិនអីទេ . . . កាលមុនកាន្តខ្ញុំរៀនពីគ្រូបាក់ជើងអីចឹងដែរ ខ្ញុំតឲ្យវាបានដូចដើមណា ! កុំភ័យ !

ពោលបណ្ដើរនាយដើរក្រឡឹងបន្ទប់បណ្ដើរដូចរកអ្វីមួយ, តាយផានសួរ:

- អ្នកប្រុសរកអី ?

- ខ្ញុំត្រូវការឈើមួយដុំ ។

នាងតាយផាន ស្ទុះទៅលុតជង្គង់ចំពោះមុខមាណពពោលអង្វរ:

– អ្នកប្រុស ! អ្នកប្រុស ! ខ្ញុំសុំអង្វរ . . . កុំធ្វើបាបគាត់ ។ អ្នកប្រុសលួង លោមប្រពន្ធគាត់បានហើយ មិនឲ្យគាត់ខឹងឬ ? ឥឡូវអ្នកប្រុសឥតទទួលគ្រោះថ្នាក់អ្វីដោយសារ គាត់ទេ សូមមេត្តាសម្លាប់គាត់តែម្ដងទៅកុំបាច់ធ្វើទារុណកម្មយូរពេក ។

មាណពលែងយល់អ្វីទាំងអស់ធ្វើភ្នែកស្ញី:

– អ្នកណាលួងលោមប្រពន្ធគាត់ ? ហេតុអីខ្ញុំត្រូវសម្លាប់គាត់ ?... អម្បាញ់មិញគាត់ហៅខ្ញុំ ឲ្យធ្វើបាបគាត់តាមចិត្ត ... យីអើ ! គេអាចសម្លាប់មនុស្សបានតាមចិត្តឬ ?

ដោយគេគំណាត់ឈើមិនបាន នាយលើកគៅអីចាប់ហែកអស់ទំហឹងបាក់ប្រាវ ។ មាណព ឥតស្មានថាខ្លួនខ្លាំងដល់ប៉ុណ្ណោះសោះ ព្រោះកម្លាំងធាតុទាំងពីរឡើងដល់កំពូលស្មើគ្នាដោយមិនដឹងខ្លួន។ នាយរអ៊ូថា គៅអីនេះមិនមាំទេ, អង្គុយទៅដួលបះជើងហើយ ។ បន្ទាប់ពីនោះនាយតឿននាង តាយជាន:

– បងតាយអង្គុយធ្វើអី ? ក្រោកឡើង !

នាយដើរទៅឯតានហៃជាមួយពាក្យថា :

– សូមលោកនៅឲ្យស្ងៀមកុំកំរើក ។

តានហៃភ្ញាក់ហានណាស់ តែពេលនេះគាត់ញញើតនាយក្រុម អង្គុយញាក់ញ័រសម្លឹងជើង គៅអីក្នុងដៃមាណពឥតព្រិចភ្នែក និកថា:

– គេមិនយកឈើមួយដុំនេះវាយយើងទេ . . . អូយ ! ប្រហែលគេរកមាត់យើងមិនឲ្យស្លាប់មិន ឲ្យរស់ទេដឹង ?

ត្បូតខានក្រុមឈានលួមានរបៀបធ្វើទារុណកម្មច្រើនបែបណាស់ របៀបយកដុំឈើញាត់មាត់ ឲ្យរើទុក្ខវេទនាហៅថា ទារុណកម្មហាមាត់ស៊េច ។ តានហៃនឹកដល់នេះរឹតតែភ័យលោះ ព្រលឹងបើកភ្នែកធំឡើង ១ តាមដំហាននាយក្រុមដែលកាន់តែខិតជិតមក ។ មាណពដើរលបៗ ដូចឆ្មារចាប់កណ្ដុរ រឹតតែធ្វើឲ្យតានហៃជឿថា គេធ្វើបាបគាត់តាមរបៀបហ្នឹង ម៉្លោះហើយគាត់ ប្រថុយលើកដៃម្ខាងប្រុងប្រទាំង ។

មាណពគ្មានយល់បំណងគាត់គិតតែហាមថា កុំកំរើក ! កុំកំរើក ! ហើយចាប់កដៃតានហៃជាប់ ។ តានហៃឈឺស្ពឹកមួយចំហៀងខ្លួនដូចពៃហៃស៊ីរបេប្បាញ់មិញដែរ កំរើកលែងរួចភ្លាម ។ មាណព

ផ្ទាប់ជើងកៅអីនឹងដៃចានហ្វៃដែលរបួសហើយ ផាកប្រាប់តាយជាន :

– បងតាយមានខ្សែទេ ? ជួយបងឲ្យខ្ញុំបន្តិចមក !

ម្ដងនេះតាយជានឆ្ងល់សួរ :

– អ្នកប្រុសពិតជាចង់តដៃឲ្យគាត់មែនឬ ?

– ហាសៗ ! តដៃដូចជាតឆ្អឹងដែរ ម៉េចចាំបាច់សួរ មើល ! គាត់ឈឺម្ល៉ឹង ៗ មិនជួយគាត់ទេហ៎ះ ?

តាយជានត្រេកអរណាស់រត់រកខ្សែមកចងដៃចានហ្វៃភ្ជាប់នឹងដុំឈើភ្លាម ។ មាណពសើចដោយពេញចិត្ត:

– ល្អ ! បងចងជាប់ណាស់តើ ! ជាប់ជាងខ្ញុំចងជើងអាវ៉ូងទៀតផង ។

នៅពេលតាយជានចងដៃគាត់ចានហ្វៃនឹកថា អាចោរនាយក្រុមអប្រិយនេះកាចសាហាវណាស់, មិនដឹងវានឹកឃើញវិធីថោកទាបបែបណាសំរាប់ដាក់ទោសយើង ? ដល់ឮគេរំឭកឈ្មោះអាវ៉ូង គាត់ទ្រាំមិនបានសួរភ្លាម:

– អាវ៉ូងជានរណា ?

– អាវ៉ូងជាឆ្កែខ្ញុំណា៎ ! តែស្ដាយណាស់, ឥឡូវវាវង្វេងបាត់ហើយ ។

ចានហ្វៃខឹងក្រោធ គំហក :

– យើងត្រកូលចានជាអ្នកក្លាហាន ជាកូនប្រុសសុខចិត្តស្លាប់មិនឲ្យកិត្តិយសធ្លាក់អាប់ឱនទេ ។ ម៉េចឯងប្រៀបផ្ទឹមយើងនឹងសត្វតិរច្ឆាន ?

មាណពតបយ៉ាងប្រញាប់ :

– ទេ ! លោកកុំយល់ច្រឡំ ហើយកុំខឹង ។ បើខ្ញុំនិយាយខុសសូមអភ័យទោស ។

ពោលហើយនាយផ្អោបដៃយ៉ាងគោរព, ចានហ្វៃញញើតកម្លាំងនាយណាស់ ស្មានថាគេផ្អោបដៃដើម្បីបញ្ជូនខ្យល់មកប្រហារគាត់ហើយ ព្រោះនាយក្រុមជាបុរសកោងកាច និងឆ្នើងឆ្នុតលោកិយ។ គាត់ផ្អៀងខ្លួនគេច ហើយខំសម្លឹងនាយក្រុមឥតព្រិច ខ្លាចប្រើអាកប្បកិរិយាផ្សេងទៀតមិនគួរ ។

មាណពពោលបន្ត :

–លោកបងត្រកូលចានឬ? សូមប្រញាប់ទៅសំរាកវិញចុះ ។ ក្ដែតតូចខ្ញុំនេះមិនបេះ

និយាយស្ដីបានជាបងខឹង, ឈប់ប្រកាន់ខ្ញុំទៅលោកបង ។

ចាន់ហៃភ្ញាក់ព្រើត :

-ម៉េចក៏ថា«ផ្ដាច់ពូជខ្ញុំ»អីចឹង? នេះជាពាក្យថ្មីសំរាប់ជេរយើងឬ ?

តាយជាននៀវធ្ងល់ដែរ ទឹកថា : អ្នកប្រុសស្រាកស្រាន្តជម្ងឺហើយបែរជាល្ងីល្ងើដូច្នេះឬ?

នាងត្រឡេកឃើញមាណពធ្វើផ្អកស្ងំដូចសញ្ជឹងគិតក៏មិចផ្អកឲ្យសញ្ញា ចាន់ហៃចៀសចេញភ្លាមទៅ , តែចាន់ហៃស្រែកខ្លាំងៗ:

- អាកូនចោរត្រកូល ស៊ី ! យើងមិនត្រូវការឲ្យឯងលើកលែងទោសទេ ! សម្លាប់យើងមក,យើងមិនខ្លាចទេ សុំប្ដូរជីវិតនឹងឯងហើយ ។ ហេតុអីមិនសម្លាប់យើងឆាប់ៗមក?

មាណពងាកមកសំឡឹងមុខគាត់ពោលដោយធ្ងល់ :

- បងឯងល្ងង់អីម្ល៉េះ ? ខ្ញុំមានចង់សម្លាប់បងឯងឯណា ? ម៉ែខ្ញុំធ្លាប់ប្រាប់ថាមនុស្សអាក្រក់សម្លាប់គេធ្វើបាបគេណាស់ , ហេតុនេះខ្ញុំមិនចង់ធ្វើមនុស្សអាក្រក់ទេខ្លាចគេស្អប់ ។

តាយជានអត់មិនបានក៏បណ្ដេញ :

- លោកនាយត្រួត ! បើលោកនាយក្រុបលើកលែងទោសហើយសូមចាកចេញពីទីនេះភ្លាមទៅ ។

ចាន់ហៃលើកដៃធ្វេងទះក្បាលដណ្ដឹងសួរថា: តើកចោរនេះល្ងីល្ងើឬយើងល្ងង់ ? តាយជានទន្ទ្រាំជើងដេញទៀត:

- ចេញទៅលោកនាយត្រួត , បង្អែបង្អង់ដល់ណាទៀត ?

ពោលផងប្រានគាត់ចេញទៅផង ។ មាណពសើចហាសៗ:

-- បងនេះម៉េចអីចឹងហ្ន៎ ! ចេះតែហៅខ្ញុំឲ្យសម្លាប់គាត់ ដូចជាខ្ញុំនេះចូលចិត្តសម្លាប់គេអ៊ីចឹង ។ ខ្ញុំមិនព្រមធ្វើមនុស្សអាក្រក់ទេបងតាយ ។

តាំងពីបានមកនៅបំរើលោកនាយក្រុប នាងតាយជានមិនដែលឃើញគាត់លើកលែងទោសឲ្យជនណាឡើយៗ នេះជាលើកដំបូងបង្អស់ដែលលោកនាយក្រុមចិត្តល្អ , នាងត្រេកអរណាស់ សើចស្ញេញពោលចំអន់ :

- អ្នកប្រុសចិត្តល្អណាស់ ! មនុស្សល្អអ៊ីចឹងទើបដណ្ដើមប្រពន្ធគេ ឲ្យត្រូវសារគេបែកបាក់ ...

ពោលដល់នេះនាងឈប់ភ្លាមទឹកញញើតនាយក្រុមក្រៃលែង ។ មាណពរឹតតែធ្ងល់សួរ :

–ខ្ញុំដណ្ដើមប្រពន្ធគេតាមរបៀបណា, ដណ្ដើមមកធ្វើអី?

តាយជានធ្វើមុខស្ញើតប :

–មនុស្សល្អមិនមែននិយាយពាក្យថោកទាបដូច្នេះទេ ។ អ្នកប្រុសធ្វើល្អមិនបានមួយសន្ទុះផង បញ្ចោញកន្ទុយបង្ហាញគេទៅហើយ ។ បើចង់ធ្វើល្អសុំធ្វើឲ្យបានយូរបន្តិចទៅអ្នកប្រុស ។

## វគ្គទី ៩

## វិជ្ជាបានសម្រេចផល

មាណពបើកភ្នែកធំ ៗ :

– នាង ... បង ... និយាយថាម៉េច ?

ពេលនេះនាយមានកម្លាំងកាយស្ដុកស្ដម្ភជាងមុន ពន្លឺភ្នែកថ្លាយង់ ហាលស្នើផ្ទេក ៗ ខុសពីធម្មតា, បណ្ដាលឲ្យតាយជានភ័យញ័រ តែថយក្រោយដល់មាត់ទ្វារបន្ទប់ដើម្បីឆ្ងាយគេ ៗ មុន ៗ ឲ្យតែនាយក្រុម « ចុះព្រេង » ប្អូន ៗ តាយជានតែងគំរាមកំហែងដោយយកក្ដីស្លាប់ជាត្រីមុខ ទើបរក្សាភាពបរិសុទ្ធបាន ៗ បើពេលនេះនាងដឹងថា នាយក្រុមមានកម្លាំងលើសដើម ម៉េះនាងភ័យប៉ុណ្ណាទៅ ? គ្រាន់តែឃើញពន្លឺភ្នែកភ្លាម នាងលែងហ៊ាននិយាយលេងក្ញាប ចំពោលញាប់មាត់ :

– អ្នកប្រុសមិនទាន់ជាស្រួលបួលទេ, សូមសំរាកចុះ ៗ

មាណពគ្រវីក្បាលមួយៗរអ៊ូម្នាក់ឯង:

– តាំងពីចុះបាកក្បាលមកខ្ញុំជួបប្រទះរឿងប្លែកណាស់មិនយល់អ្វីសោះហើយ ៗ ហ៊ី ! ខ្ញុំល្ងីមែន ... ឥតយល់សប្ដិទេឬ ? . . .

ពោលបណ្ដើរប្រឹងចាប់បង្អែកកៅអីបណ្ដើរ ប្ញាក់ប្រាវរបេះជាពីរ ហើយបែកជាបន្ទះ តូចៗជ្រុះតាមចន្លោះដៃទៅដីអស់ ៗ មាណពភ្ញាក់ព្រញ្ញាន់ពោល :

–យីម៉េចកៅអីផុយម្ល៉េះ ? ធ្វើពីឈើអីហ្នឹង ?

(នៅមានត)

Khmer Story Lovers

តំកល់ទុកតាមលេខ ៣០៤ ចុះថ្ងៃទី ២២-៥-៧០ បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់